មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ផាន ដា ភេទស្រី អាយុ៩៥ឆ្នាំ**

**មុខងារសម័យខ្មែរក្រហម“កងចល័តស្រុក”**

**ស្រុកកំណើតនៅភូមិសង្រ្គាម ឃុំសង្រ្គាម ស្រុកស្ទោង ខេត្តកំពង់ធំ**

**រស់នៅភូមិមានជ័យ ឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ចាន ប្រុញ**

**០០:២០:១៣**

**១៣ទំព័រ**

ប្រុញៈ អ៊ុំឥឡូវខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ខ្ញុំមកដើម្បីប្រមូលចងក្រងជាឯកសារពាក់ព័ន្ធនឹងជីវិតរស់នៅរបស់អ៊ុំ តស៊ូពីសម័យខ្មែរក្រហមមករហូតដល់រាល់ថ្ងៃ ហើយការសួរនាំនេះដើម្បីចងក្រងជាឯកសារទុកឲ្យកូនចៅជំនាន់ក្រោយបានដឹងពីការតស៊ូរបស់អ៊ុំមក ជីវិតរស់នៅមកដល់រាល់ថ្ងៃនេះមានអីចឹង ។ ដំបូងខ្ញុំសុំថតជាសំលេងដើម្បីទុកជាឯកសារដើម្បីកត់ត្រាបន្ថែមអីទៀត អ៊ុំអត់អីទេ?

ដាៈ តែខ្ញុំអត់បានពេលយូរទេ ។

ប្រុញៈ បាទ! អត់អីទេ ។ អីចឹងខ្ញុំសុំថតជាសំលេងអត់អីទេ?

ដាៈ ថតអីទេ មិនបាច់ថតទេ ប្រញាប់ដែរ ។

ប្រុញៈ អត់ទោស អ៊ុំឈ្មោះអីដែរ?

ដាៈ ខ្ញុំឈ្មោះ ផាន ដា ។

ប្រុញៈ អ៊ុំរាល់ថ្ងៃអាយុប៉ុន្មានហើយ?

ដាៈ ខ្ញុំអាយុ៩៥ ។

ប្រុញៈ អ៊ុំមានស្រុកកំណើតនៅណាដែរ?

ដាៈ កំពង់ធំ ។

ប្រុញៈ ខេត្តកំពង់ធំ ស្រុកអីគេអ៊ុំ?

ដាៈ ស្រុកស្ទោង ។

ប្រុញៈ ឃុំ?

ដាៈ ឃុំសង្រ្គាម ។

ប្រុញៈ ភូមិ?

ដាៈ ភូមិសង្រ្គាមដែរ ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ប្រុញៈ គ្រួសារអ៊ំឈ្មោះអីគេ?

ដាៈ យ៉ឹម ។

ប្រុញៈ គាត់អាយុប៉ុន្មានដែរ?

ដាៈ អាយុហាដែរ ។

ប្រុញៈ អ៊ំពេលថ្ងៃមានកូនចៅប៉ុន្មានដែរ?

ដាៈ ២នាក់ ។

ប្រុញៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ដាៈ ស្រីទាំងពីរ ។

ប្រុញៈ ហើយអ៊ំរៀនដល់ថ្នាក់ណាដែរ?

ដាៈ ខ្ញុំអត់ចេះអក្សរដែរ ។

ប្រុញៈ អត់បានរៀនអ៊ំ?

ដាៈ ចា៎!

ប្រុញៈ អីចឹងពេលថ្ងៃអ៊ំមកនៅក្នុងភូមិអីគេ?

ដាៈ ភូមិមានជ័យ ។

ប្រុញៈ ឃុំ?

ដាៈ បាក់អន្លង់ ។

ប្រុញៈ ស្រុក?

ដាៈ ស្រុកត្រពាំងប្រាសាទ ។

ប្រុញៈ ខេត្ត?

ដាៈ ខេត្តឧត្តរមានជ័យ ។

ប្រុញៈ អ៊ំក្នុងអំឡុងឆ្នាំ៧០មក អ៊ំនៅស្រុកណា?

ដាៈ ខ្ញុំនៅស្រុកនោះដែរ ។

ប្រុញៈ ពេលដែលមានការទម្លាក់សម្តេចសីហនុពីអំណាច តើអ៊ំនៅណា?

ដាៈ ខ្ញុំនៅស្រុកដែរកាលនោះ ។

ប្រុញៈ អ៊ំនៅស្រុក?

ដាៈ ចា៎! ខ្ញុំអត់ទាន់មកព្រៃទេ ។

ប្រុញៈ ក្នុងឆ្នាំ៧០ត្រូវទេអ៊ំ?

ដាៈ ខ្ញុំមក៧៥ ។

ប្រុញៈ ចុះ៧១-៧២អ៊ំនៅណាវិញ?

ដាៈ ខ្ញុំនៅស្រុកដែរ ខ្ញុំនៅផ្ទះខ្ញុំ ។

ប្រុញៈ ចុះអ៊ំចូលរួមជាមួយចលនារបស់ខ្មែរក្រហមក្នុងឆ្នាំណា?

ដាៈ ឆ្នាំ៧៥ ។

ប្រុញៈ អីចឹងឆ្នាំ៧៣-៧៤អ៊ំ?

ដាៈ ខ្ញុំនៅស្រុក ។

ប្រុញៈ អត់បានធ្វើអីទេអីចឹង?

ដាៈ ចាំ! អត់ទេ ។

ប្រុញៈ ពេលដែលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ អ៊ំទៅណាវិញ?

ដាៈ កាលហ្នឹង៧៥ខ្ញុំចូលក្នុងព្រៃ ។

ប្រុញៈ ម៉េចបានចូលព្រៃ?

ដាៈ ខ្ញុំខ្លាច ។

ប្រុញៈ ៧៥ហ្នឹង?

ដាៈ ចាំ! ចូលមកផ្តាច់ខ្លួនមកនៅខ្មែរក្រហម ។

ប្រុញៈ ព្រោះវៀតណាមចូលមក៧៩ហើយ?

ដាៈ ចាំ! តែខ្ញុំមកមុន ។

ប្រុញៈ មកមុន៧៩ទៀត?

ដាៈ ចាំ! ខ្ញុំមកខ្ញុំរត់ទៅនៅខាងម៉ាឡៃ ។

ប្រុញៈ ឆ្នាំ៧៥?

ដាៈ ចាំ!

ប្រុញៈ អ៊ំច្បាស់ឆ្នាំហ្នឹងអត់? ច្បាស់ឆ្នាំ៧៥ហ្នឹងអត់មកដល់ម៉ាឡៃ?

ដាៈ អូ! មិនទាន់ដល់ទេ ៧៥ខ្ញុំនៅស្រុក នៅក្នុងភូមិ ដល់ពេល៨៩ដឹងខ្ញុំរត់មកនៅម៉ាឡៃ ។

ប្រុញៈ ៨៩វិញ?

ដាៈ ចាំ! ៨៩ ។

ប្រុញៈ អីចឹងក្នុងសម័យ៣ឆ្នាំ?

ដាៈ សម័យ៣ឆ្នាំខ្ញុំនៅស្រុក តែខ្ញុំនៅចូលរួមគស៊ូនឹងគេ តែខ្ញុំនៅនឹងភូមិ គេថានារីភូមិ នារីឃុំមួយសារហ្នឹង ។

ប្រុញៈ អត់ទោសអ៊ំម៉ិញភូមិអីគេ?

ដា: ភូមិសង្គ្រាម ។

ប្រុញ: ភូមិសង្គ្រាមឆ្នាំ៧៥អ៊ំនៅភូមិសង្គ្រាមហ្នឹងទេ ពីណាគេមេភូមិ?

ដា: ខ្ញុំអត់សូវចាំ ។

ប្រុញ: ពេលហ្នឹងអ៊ំធ្វើអីគេ?

ដា: ខ្ញុំអត់មានធ្វើអីទេ គេហៅទៅប្រជុំក៏ទៅប្រជុំនឹងគេ ។

ប្រុញ: គេប្រជុំរឿងអី?

ដា: ប្រជុំរឿងដូចថាធ្វើតស៊ូ ។

ប្រុញ: គេនិយាយថាម៉េច?

ដា: តស៊ូធ្វើឈ្លប ឈ្លបនារី ឈ្លបបុរស អីចឹងឯង ។

ប្រុញ: គេហៅប្រជុំញឹកទេ?

ដា: អត់ទេ ខ្ញុំនៅអត់សូវប្រជុំញឹកប៉ុន្មានទេជំនាន់ខ្ញុំ ដល់ក្រោយមកទៀតទេ ដល់ខ្ញុំចូលក្នុងព្រៃ ហើយបានគេប្រជុំញឹក ។

ប្រុញ: អ្នកដែលហៅអ៊ំប្រជុំគាត់ឈ្មោះអី?

ដា: ឈ្មោះអីទេ ខ្ញុំភ្លេចឈ្មោះ ។

ប្រុញ: គាត់ឋានៈគាត់ធ្វើអីគេ?

ដា: ឃុំ ។

ប្រុញ: ប្រធានឃុំ?

ដា: ចា៎! តែស្លាប់ហើយខាងស្ត្រី ។

ប្រុញ: គាត់ស្រី?

ដា: ស្លាប់ហើយ ។

ប្រុញ: ពេលប្រជុំហ្នឹង ប្រជុំមួងគ្នាច្រើនទេ?

ដា: ប្រជុំគ្នាច្រើន ។

ប្រុញ: ហ្នឹងមុនឆ្នាំ៧៥ ?

ដា: ចា៎! ប្រជុំគ្នាច្រើន ដូចថាតាមភូមិមួយៗ ដូចថាមានខាងស្ត្រី ប្រជុំឲ្យយើងតស៊ូនឹងគេ ។

ប្រុញ: ពេលហ្នឹងអ៊ំអាយុប៉ុន្មាន?

ដា: ខ្ញុំកាលហ្នឹងអាយុ១៨ឆ្នាំ ហើយខ្ញុំអត់ដាច់ចិត្តពីម៉ែខ្ញុំទេ គេចេះតែជំរុញឲ្យមក ឲ្យខ្ញុំតស៊ូនឹងគេ ។

ប្រុញ: អ្នកដែលហៅអ៊ំប្រជុំអាយុប្រហែលប៉ុន្មាន?

ដា៖ គាត់ចាស់ហើយ គាត់កូនឡើងធំៗប៉ុនក្មួយឯង ។

ប្រុញ៖ តែស្រុកភូមិជាមួយគ្នាទេ?

ដា៖ ចា៎! គាត់ធ្វើមេភូមិ បន្ទាប់ពីឃុំមកគាត់ ។

ប្រុញ៖ ភូមិហ្នឹងឈ្មោះភូមិសង្គ្រាមតាំងពីហ្នឹងមក?

ដា៖ ចា៎!

ប្រុញ៖ ពីមុនមកមានចូលលុកលុយភូមិហ្នឹងឬម៉េចបាននាំឲ្យមានការតស៊ូ?

ដា៖ មាន ដូចថាគេតស៊ូលន់ នល់ ទម្លាក់សីហនុ គេជម្លៀសប្រជាជនរបាត់របាយទៅ ។

ប្រុញ៖ អ៊ីចឹងប្រជុំហ្នឹងកំឡុងពេលដែលក្រោយគេទម្លាក់សម្តេចសីហនុហ្នឹងហើយ?

ដា៖ ចា៎!

ប្រុញ៖ ហើយគេប្រាប់ថាម៉េច?

ដា៖ ខ្ញុំមិនសូវចាំទេ រឿងគេប្រជុំ គេនិយាយរឿងតស៊ូ តែខ្ញុំមិនសូវចាំ ភ្លេចភ្លាំងដែលកាលហ្នឹង ។

ប្រុញ៖ ថាទម្លាក់ហ្នឹងគេថាម៉េចអ៊ី? មានន័យថាត្រូវតែតស៊ូដណ្តើមអំណាចឲ្យសម្តេចសីហនុវិញឬយ៉ាងម៉េច?

ដា៖ អត់ទេ ដូចថាតស៊ូដណ្តើមអំណាចឲ្យនេះតែម្តង ហ្នឹងគេដេញយើងចេញពីភូមិ ដូចថាគេជម្លៀសយើងចេញ ។

ប្រុញ៖ ខាងណាជាអ្នកជម្លៀស?

ដា៖ ខាងខ្មែរក្រហម ។

ប្រុញ៖ ក្នុងប្រហែលឆ្នាំណាដែលអ៊ី?

ដា៖ ៧៤-៧៥ ភ្លេចដែលខ្ញុំមិនសូវចាំ ។

ប្រុញ៖ ពេលហ្នឹងគេមានលើកពីរឿង វៃ មានពាក្យខ្មាំងពេលកាលហ្នឹង?

ដា៖ មាន មិនអត់ទេ មានថាខ្មាំង ដូចថាយើងអត់តស៊ូថាយើងខ្មាំង ។

ប្រុញ៖ ហើយខ្មាំងៗគេសំដៅលើពីណា?

ដា៖ មិនដឹងសំដៅលើពីណាខ្ញុំមិនសូវយល់ដែរកាលហ្នឹង រាងស្ទើរដែលមិនសូវចាប់អារម្មណ៍ ។

ប្រុញ៖ ហើយសម័យហ្នឹងមានជនជាតិចាម នៅជាមួយគ្នាទេ?

ដា៖ ខាងខ្ញុំអត់មានទេ ។

ប្រុញ៖ ចុះជនជាតិវៀតណាម?

ដា៖ អត់មាន មានតែខ្មែរ ខ្មែរសុទ្ធខាងខ្ញុំ ចិន ចាម យួន អត់មានសោះ ។

ប្រុញៈ ពេលគេប្រជុំគេមានលើករឿងជនជាតិចាម វៀតណាម ?

ដាៈ អត់មានលើក ។

ប្រុញៈ ចុះលន់ នល់? គេមានលើកទាហានលន់ នល់?

ដាៈ គេលើកទាហានលន់ នល់ គេប្រាប់ថាទាហានលន់ នល់ ។

ប្រុញៈ អីចឹងពេលហ្នឹងអ៊ំនៅខាងលន់ នល់ ឬនៅខាងខ្មែរក្រហម?

ដាៈ ខ្ញុំអត់ទាន់បែងចែកច្បាស់ទេកាលនោះ អាចនៅខាងខ្មែរក្រហម ។

ប្រុញៈ អីចឹងបានន័យថាពេលប្រជុំហ្នឹង ខ្មែរក្រហមហៅប្រជុំទេ?

ដាៈ ចា៎!

ប្រុញៈ អីចឹងបានន័យថាពាក្យខ្មាំងហ្នឹងគេសំដៅទៅខាងលន់ នល់ ឬម៉េច?

ដាៈ មិនដឹងគេសំដៅទៅខាងណា ខាងលន់ នល់ ដឹង ។

ប្រុញៈ ប៉ុន្តែពេលហ្នឹងគេនិយាយមានលក្ខណៈថាខឹងសម្បារដែលអត់ ពេលដែលគេហៅយើងប្រជុំ?

ដាៈ កាលជំនាន់នោះមិនទាន់មានពាក្យកំហឹង ។

ប្រុញៈ ភាគច្រើនគេថាម៉េចដែរ?

ដាៈ ភាគច្រើនគេនិយាយថាតស៊ូ ។

ប្រុញៈ ដឹងថាតស៊ូ?

ដាៈ ចា៎!

ប្រុញៈ គ្រាន់តែថាតស៊ូប្រឆាំងជាមួយពីណា អត់មាននិយាយទេ?

ដាៈ ចា៎! អត់ទេ ។

ប្រុញៈ ដល់អីចឹងរកសត្រូវម៉េចឃើញទៅ?

ដាៈ រកអត់ឃើញទេខ្ញុំ ។

ប្រុញៈ បើអត់ប្រាប់ថា?

ដាៈ ខ្ញុំអត់ទាន់ដឹងដែរកាលនោះ ខ្ញុំអត់ដឹងថាខាងណាសត្រូវ ខាងណាមិនសត្រូវខ្ញុំអត់ដឹងទេ ខ្ញុំរាងស្ទើរដែរ ដូចថាជំនាន់នោះ យើងមិនដូចសម័យឥឡូវគេចេះដឹង ជំនាន់នោះនៅឆោត ។

ប្រុញៈ ហ្នឹងប្រជុំនៅក្នុងភូមិ-ឃុំហ្នឹងអ៊ំ?

ដាៈ ចា៎!

ប្រុញៈ ដល់ពេលគេដណ្តើមបានទៅ អ៊ំទៅនៅណាវិញ?

ដាៈ ខ្ញុំនៅកងចល័ត ។

ប្រុញៈ	កងចល័តនៅភូមិ?

ដាៈ	ស្រុក ។

ប្រុញៈ	ស្រុកណា?

ដាៈ	ស្រុកស្មោង ។

ប្រុញៈ	ស្រុកស្មោង?

ដាៈ	ចាំ!

ប្រុញៈ	ស្រុកស្មោងហ្នឹងអ៊ំនៅស្រុកតែម្តង ឬនៅណា?

ដាៈ	នៅស្រុកកងចល័ត ។

ប្រុញៈ	ពីណាគណៈស្រុក?

ដាៈ	គណៈស្រុកកាលនោះ ក្មួយអើយផ្លាស់២-៣ជំនាន់មិនដឹងពីណា ពីណី ។

ប្រុញៈ	ដំបូងពីណាគេ?

ដាៈ	ភ្លេចឈ្មោះ ។

ប្រុញៈ	អ៊ំចាំពីណាដែលធ្វើគណៈស្រុក?

ដាៈ	ខ្ញុំអត់ចាំ ខ្ញុំអត់នៅជាប់នឹងស្រុក តែស្រុកគ្រប់គ្រងដែរ តែមានអ្នកនៅលើទៀត ខ្ញុំភ្លេចឈ្មោះគេដែរ ។

ប្រុញៈ	ពេលហ្នឹងអ៊ំធ្វើអីគេ?

ដាៈ	ខ្ញុំអត់មានធ្វើអីទេ ដូចកូនក្មេងនៅដើរតាមគេនៅឡើយ ខ្ញុំដូចជាអត់ចាំគណៈស្រុក ។

ប្រុញៈ	គេដែលហៅទៅប្រជុំញឹកញាប់?

ដាៈ	អត់ទេ អត់ដែលទេ តែមេៗទៅ ។

ប្រុញៈ	ចុះក្រោយមកឆ្នាំ៧៩ អ៊ំមកណាវិញ?

ដាៈ	ឆ្នាំ៧៩ ខ្ញុំរត់មកនៅព្រំដែនថៃ ។

ប្រុញៈ	ម៉េចបានរត់មកអីចឹង?

ដាៈ	ខ្លាចយួន អត់ហ៊ានទៅស្រុកជងខ្ញុំ ̈

ប្រុញៈ	ម៉េចបានខ្លាចយួន?

ដាៈ	ខ្ញុំខ្លាចឡើង បើថាយួនអារក ខ្លាច ។

ប្រុញៈ	ពីណាគេអ្នកប្រាប់ថាយួនអារក?

ដាៈ	ចិត្តសាស្រ្តចេះតែថាទៅ ខ្ញុំអីចេះតែខ្លាចអត់ហ៊ានចូលស្រុក ។

ប្រុញៈ	មានន័យថាឆ្នាំ៧៩ខ្លាចបំផុតរឿងយួន?

ដា៖ ចា៎! ខ្លាច ។

ប្រុញ៖ ដោយសារយើងដឹងថាខ្មែរក្រហមប្រឆាំងជាមួយវៀតណាម យួនហ្នឹងតែម្តងឬម៉េច?

ដា៖ យើងនៅក្រោមការគ្រប់គ្រងរបស់គេ គេថាម៉េចយើងទៅអីចឹង ។

ប្រុញ៖ គេប្រាប់ហ្នឹងប្រាប់ថាម៉េចខ្លះ?

ដា៖ គេគ្រាន់តែថាមិនបាច់ចូលស្រុកទេខ្លាចយួនអារក ខ្លាចយួនសម្លាប់ ។

ប្រុញ៖ តែគួរឲ្យឆ្ងល់ថាហេតុអីបានគេយកថាយួនសម្លាប់?

ដា៖ យើងមិនដឹងដែរកាលហ្នឹង ។

ប្រុញ៖ ពេលចន្លោះហ្នឹងគេមានលើករឿងហ្នឹង អ៊ំនិយាយមុនហ្នឹងថាក្រោយ៧៩គេលើកឈ្មោះរឿងយួនច្រើន?

ដា៖ ចា៎!

ប្រុញ៖ គេលើកម៉េចទៅ?

ដា៖ គេមានលើកម៉េច ចិត្តសាស្ត្រយើងអីចឹង ។

ប្រុញ៖ គេមានប្រាប់ថាឲ្យយើងប្រឆាំងជាមួយយួន?

ដា៖ ចា៎!

ប្រុញ៖ គេប្រាប់ថាម៉េចទៅ?

ដា៖ គេថាធ្វើសង្គ្រាមជាមួយយួន គេថាអត់មានធ្វើជាមួយខ្មែរទេ ។

ប្រុញ៖ ពេលហ្នឹងអ៊ំមានជួបគេចាប់បានយួន?

ដា៖ អត់ទេ ខ្ញុំមិនដែលទេ ខ្ញុំនៅតែលើភ្នំដងរែកនោះ ។

ប្រុញ៖ ពេលដែលអ៊ំចូលគេថាយួនអារក ពីណាគេអ្នកប្រាប់?

ដា៖ ដូចថាមេគេគ្រប់គ្រងយើង ។

ប្រុញ៖ គាត់ឈ្មោះអីគេ?

ដា៖ មិនដឹងឈ្មោះអីទេ លឺតគ្នា ។

ប្រុញ៖ អ៊ំអាចចាំឈ្មោះតែបន្តិចក៏បាន?

ដា៖ ខ្ញុំអត់ចាំទេ ទាល់តែខ្ញុំនៅជាមួយតាជុំ បានខ្ញុំស្រួល ។

ប្រុញ៖ តាជុំ មានដែលនិយាយទេ?

ដា៖ អត់ទេ មិនដែលនិយាយអីទេ និយាយតែពីរឿងផ្តាច់ខ្លួនឲ្យស្រុកយើងចប់សង្គ្រាម គាត់មិនចង់ច្បាំងគ្នា ចង់តែឆាប់ចប់ ពួកខ្ញុំចេះតែស្តាប់គាត់ទៅ តាមគាត់គ្រប់គ្រង ផ្តាច់ខ្លួនជាមួយគាត់ទៅ ។

ប្រុញៈ ពេលផ្តាច់ខ្លួនអ៊ំមកម្តុំណា?

ដាៈ មកនៅតាមនេះ ដំបូងខ្ញុំនៅសាលា ក្រោយមកគាត់យកទៅនៅទំនប់ដាច់ កាលនោះគាត់ផ្តាច់ខ្លួនមុនពួកខ្ញុំ គាត់យកទៅទុកទំនប់ដាច់គាត់ផ្តាច់ខ្លួន ដល់ពេលគាត់ចូលទៅផ្តាច់ខ្លួនទៅគាត់ហៅទ័ពឲ្យយកពួកខ្ញុំមកនៅត្រពាំងប្រាសាទវិញ ។

ប្រុញៈ អ៊ីចឹងគាត់ផ្តាច់ខ្លួនមុន?

ដាៈ ចា៎!

ប្រុញៈ បានអ៊ំមកតាមក្រោយទៅ?

ដាៈ ចា៎! តែនៅក្រោមការគ្រប់គ្រងរបស់គាត់ ។

ប្រុញៈ ពេលដែលតាជុំ គាត់មកមកវិញ មានពីណាគ្រប់គ្រងនៅកន្លែងហ្នឹង?

ដាៈ មានអ្នកគ្រប់គ្រង ។

ប្រុញៈ គាត់ឈ្មោះអីគេ?

ដាៈ ខ្ញុំនៅជាមួយតាម៉ុត ស្លាប់បាត់ហើយ ។

ប្រុញៈ តាម៉ុត ឋានៈគាត់អីគេ?

ដាៈ កងវរៈ ប្តីខ្ញុំនៅជាមួយគាត់ ។

ប្រុញៈ ប្តីអ៊ំមីញឈ្មោះអីគេ?

ដាៈ ឈ្មោះ យឹម ។

ប្រុញៈ គាត់ធ្វើអីគេពេលនៅជាមួយតាម៉ុត?

ដាៈ គាត់អត់មានធ្វើអីទេ មហាជនធម្មតា ។

ប្រុញៈ ហើយដល់ពេលណាបានគេឈប់និយាយរឿងយួន?

ដាៈ ផ្តាច់ខ្លួនគេឈប់ហើយ ។

ប្រុញៈ ក្នុងកំឡុងពេលផ្តាច់នៅនិយាយដែល?

ដាៈ អត់មាននិយាយទេ ចប់ ដូចថាចប់ទៅស្រួល ។

ប្រុញៈ ខ្ញុំចង់សួររឿង ពេលដែលអ៊ំមកពីនោះតាជុំអ្នកដឹកនាំឲ្យចូលមក?

ដាៈ ចា៎!

ប្រុញៈ ក្រោយពីផ្តាច់ខ្លួនហើយអ៊ំមកនៅដល់ណាវិញ?

ដាៈ ពីនោះនៅអូរស្វាយ ។ អូរស្វាយនេះ ហើយគាត់យកទៅនៅត្រពាំងប្រាសាទ ។

ប្រុញៈ ខ្ញុំជួបអ៊ំមួយនោះគាត់ថាពេលដែលគាត់រត់ចូលព្រៃ ភាគច្រើនខ្លាចយួន ព្រោះយួនរកចាប់កូនក្រមុំ មានអ៊ីចឹងទេ?

ដា៖ អត់ទេ ខ្ញុំអត់ខ្លាចរឿងចាប់កូនក្រមុំ ខ្លាចយួនចាប់សម្លាប់តែម្តង រឿងកូនក្រមុំមិនខ្លាចទេ។

ប្រុញ៖ អីចឹងសម័យហ្នឹងរត់ចូលព្រៃគឺខ្លាចតែយួនមួយ?

ដា៖ ចា៎!

ប្រុញ៖ អត់មានខ្លាចខាងរដ្ឋាភិបាល?

ដា៖ អត់ខ្លាចទេ រដ្ឋាភិបាល។

ប្រុញ៖ ខ្លាចតែយួនមួយ?

ដា៖ ខ្លាចតែយួន។

ប្រុញ៖ គេផ្សេងៗគេខ្លាចយួនដែលឬម៉េច?

ដា៖ ខ្លាចដូចតែគ្នា។

ប្រុញ៖ ប៉ុន្តែមូលហេតុអីខ្លាចពិតប្រាកដអត់ទាន់ដឹងទេ គ្រាន់តែថ្នាក់លើគេប្រាប់អីចឹង? គេហៅប្រជុំយួនអារក?

ដា៖ មិនខ្លាចម៉េចកូនតូចផង សសៃខ្ចី ចេះតែខំទៅ។

ប្រុញ៖ តែអ៊ីដែលឃើញយួនតែម្តង?

ដា៖ អត់ដែលឃើញទេ មិនដែលឃើញពិតទេ។

ប្រុញ៖ ឧទាហរណ៍ថាថ្នាក់លើមានប្រាប់ថាបើសិនជាចាប់យួនបានត្រូវមានធ្វើម៉េចទេ?

ដា៖ អត់មានធ្វើម៉េចទេ អត់សម្លាប់ផង។

ប្រុញ៖ គេមានដែលនិយាយថាបើសិនជាចាប់យួនបាន ត្រូវធ្វើម៉េចទេ?

ដា៖ គេថាត្រូវធ្វើនយោបាយ។

ប្រុញ៖ ធ្វើម៉េចទៅអ៊ី?

ដា៖ មិនដឹងគេធ្វើម៉េច មិនដឹងគេធ្វើនយោបាយយ៉ាងម៉េច ដូចថាគេអ្នកនៅយាមកាម ខ្ញុំមិនសូវដឹងដែរ។

ប្រុញ៖ គេយល់ថាយួនហ្នឹងខ្មាំងហ្នឹងឬម៉េចដែរ ពេលក្រោយ៧៩ហ្នឹង?

ដា៖ គេថាខ្មាំង។

ប្រុញ៖ ខ្មាំងពេលគេចាប់បាន គេធ្វើយ៉ាងម៉េចទៅអ៊ី?

ដា៖ បើខាងខ្ញុំអត់មានឃើញសម្លាប់ទេ។

ប្រុញ៖ គ្រាន់តែចាប់យកទុក?

ដា៖ ចា៎! ចាប់ទុក អត់មានថាចាប់ហើយសម្លាប់អត់ទេ ឲ្យបាយហូបឆ្អែតដូចតែយើងដែរ។

ប្រុញ៖ ពេលហ្នឹងមានចាប់បានទេ?

ដា៖ ចាប់បាន ។

ប្រុញ៖ ចាប់បានខ្លះដែរ?

ដា៖ ចាំ!

ប្រុញ៖ យួនធ្វើម៉េចបានចាប់បាន?

ដា៖ គេអ្នកនៅមុខ ដូចថាគេទៅវែសមរភូមិគេចាប់បាន គេបញ្ជូនមកលើ ។

ប្រុញ៖ ពួកហ្នឹងសុទ្ធតែទាហានឬយ៉ាងម៉េច?

ដា៖ ទាហាន ។

ប្រុញ៖ មានប្រជាជនធម្មតាទេ?

ដា៖ អត់មានទេ ។

ប្រុញ៖ ចុះបើប្រជាជនធម្មតា? ប្រជាជនជាវៀតណាម ជាយួន?

ដា៖ អត់មានឃើញទេ ។

ប្រុញ៖ បើឃើញចាប់ទេ?

ដា៖ ខ្ញុំ?

ប្រុញ៖ គេទូទៅ?

ដា៖ ដឹងអី មិនដឹងចិត្តគេចាប់អត់ ខ្ញុំអត់ដឹងដែរ ។

ប្រុញ៖ តែគេមានប្រាប់ឲ្យចាប់ទេ?

ដា៖ ដូចមិនលឺថា ។

ប្រុញ៖ ពេលប្រជុំគេអត់មានប្រាប់ថា?

ដា៖ អត់ទេ ។

ប្រុញ៖ បើសិនទាហានចាប់?

ដា៖ ទាហានគេទៅមុខគេចាប់ តែពួកខ្ញុំអ្នកនៅក្រោយអត់ដឹង គ្រាន់តែគេចាប់មកឃើញ ។

ប្រុញ៖ ហ្នឹងក្នុងអំឡុងឆ្នាំណា? អំឡុង៨០មានការចាប់យួន?

ដា៖ ខ្ញុំមិនសូវចាំ ។

ប្រុញ៖ អ៊ំចូលព្រៃភ្លាមត្រូវទេ?

ដា៖ ចាំ?

ប្រុញ៖ ក្រោយមកតិចមានការចាប់យួនហ្នឹង?

ដា៖ យូរដែរ ដូចថាអាច៩០ ។

ប្រុញ៖ ៩០មានគេចាប់ដែរ?

ដា៖ ចាំ!

ប្រុញ៖ ចុះកូនក្មេងយួន?

ដា៖ អត់ដែលឃើញទេ កូនក្មេងយួន ។

ប្រុញ៖ ឃើញទាហានយួន?

ដា៖ ឃើញតែទាហានយួន បើកូនក្មេងមិនដែលឃើញ ។

ប្រុញ៖ អ៊ំនៅពេលហ្នឹងមានធ្វើបុណ្យធ្វើទាហាន?

ដា៖ កាលសម័យនោះ?

ប្រុញ៖ បាទ!

ដា៖ ធ្វើតែអត់មានលោក មានតែចាស់ៗ ។

ប្រុញ៖ សុទ្ធតែអ្នកកាន់សាសនាព្រះពុទ្ធ?

ដា៖ ចាំ!

ប្រុញ៖ ចុះអ្នកកាន់សាសនាឥស្លាម?

ដា៖ អត់ដែលមានទេ ។

ប្រុញ៖ ចុះបើមានឲ្យកាន់ដែលអត់?

ដា៖ អត់ដឹងដែរ ។

ប្រុញ៖ គេអត់មានប្រាប់?

ដា៖ គេអត់ដែលនិយាយរឿងអីចឹងទេ គ្រាន់តែថាពេលធ្វើបុណ្យ ធ្វើទានមានចាស់ទុំ ។

ប្រុញ៖ អីចឹងនៅជាមួយអ៊ំអត់មានជនជាតិចាម ជនជាតិអី?

ដា៖ អត់មាន ។

ប្រុញ៖ សុទ្ធតែខ្មែរយើងសុទ្ធ?

ដា៖ ចាំ! សុទ្ធតែខ្មែរ រឿងខ្មែរ-ចាមទើបតែឥឡូវទេ ។

ប្រុញ៖ ពីមុនអត់មានចាមទេ?

ដា៖ អត់មានទេ ។

ប្រុញ៖ មានតែពាក្យខ្មែរ?

ដា៖ ចាំ! មានតែខ្មែរៗ ។

ប្រុញ៖ បើសិនជាមានចាមនៅជាមួយយ៉ាងម៉េច?

ដា៖ មានយ៉ាងម៉េច នៅជាមួយនៅទៅ ។

ប្រុញ៖ បើយួននៅអត់បាន?

ដា៖ មិនដឹងដែរ មិនដែលឃើញ ខ្ញុំនៅតែក្រោយៗមិនដែលឃើញ ។

ប្រុញ៖ អីចឹងអត់អីទេបើអ៊ំប្រញាប់ ខ្ញុំចល់រំខានអ៊ំយូរ ។

ដា៖ ខ្ញុំប្រញាប់ដែរ ។

ប្រុញ៖ អរគុណច្រើនអ៊ំ ។

ដា៖ ចា៎!

ចប់